# របាយការណ៍អតិផរណាប្រចាំខែវិច្ឆិកា ឆ្នាំ២០១០
# សម្រាប់កិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុលើកទី១៩

ភ្នំពេញ ថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១១

## I. ស្ថានភាពអតិផរណាខែវិច្ឆិកា ឆ្នាំ២០១០

អតិផរណាខែលើខែ ក្នុងខែវិច្ឆិកានេះ មានកម្រិត -១% បន្ទាប់ពីមានអត្រាវិជ្ជមានជាបន្តបន្ទាប់អស់រយៈ ៤ ខែ ហើយក៏ជាកម្រិតអវិជ្ជមានទាបជាងគេក្នុងអំឡុង ១១ ខែ កន្លងមកនៃឆ្នាំ ២០១០ ។ ក្នុងឆ្នាំនេះ អតិផរណាបានកើនដល់ចំណុចកំពូលប្រចាំឆ្នាំស្មើ ១,៤% នាខែតុលា ។ សូមកត់សម្គាល់ថា អត្រាអតិផរណាមធ្យមប្រចាំខែក្នុងអំឡុង ១១ ខែ ឆ្នាំ២០១០ មានកម្រិតត្រឹម ០,៣% ប៉ុណ្ណោះ ដែលទាបជាងអត្រាអតិផរណាមធ្យមប្រចាំខែនារយៈពេលដូចគ្នាកាលពី ៣ ឆ្នាំមុន ដែលមានអត្រា ០,៥% ១,៥% និង ១,១% នៅឆ្នាំ ២០០៩ ២០០៨ និង ២០០៧ រៀងគ្នា ។ ពោលគឺ ទោះបីជាថ្លៃទំនិញសំខាន់ៗនៅទីផ្សារអន្តរជាតិដែលមានឥទ្ធិពលមកលើថ្លៃទំនិញក្នុងស្រុក ដូចជា ថ្លៃប្រេងឥន្ធនៈដែលជាទំនិញនាំចូលសុទ្ធសាធរបស់កម្ពុជា មានការឡើងថ្លៃខ្លាំងក៏ដោយ ក៏ស្ថានភាពអតិផរណាឆ្នាំ ២០១០ នេះ នៅតែមានស្ថិរភាពប្រសើរជាងគ្រាដូចគ្នានា ៣ ឆ្នាំកន្លងមក ។




គិតតាមបម្រែបម្រួលខែលើខែ នាខែវិច្ឆិកា ឆ្នាំ ២០១០ នេះ ក្នុងចំណោមថ្លៃទំនិញទាំង១២ ក្រុម មាន៩ ក្រុមបានថយចុះ ២ក្រុមបានកើនឡើង និង ១ ក្រុមមិនមានការប្រែប្រួល ។ ក្រុមទំនិញដែលបានចុះថ្លៃមាន ក្រុមម្ហូបអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង ១,៤% ក្រុមភោជនីយដ្ឋាន ១,៣% ក្រុមដឹកជញ្ជូន ១,១% ក្រុមគមនាគមន៍ ១% ក្រុមការកម្សាន្តនិងវប្បធម៌ ០,៨% ក្រុមផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និង ឥន្ធនៈដទៃទៀត ០,៧% ក្រុមភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ ០,៦% ក្រុមសម្លៀកបំពាក់និងស្បែកជើង ០,៤% ក្រុមគ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់ក្នុងគ្រួសារ និងការថែទាំផ្ទះជា



ប្រចាំ ០,១% ។ ចំណែកឯក្រុមទំនិញដែលឡើងថ្លៃរួមមាន ក្រុមទំនិញនិងសេវាផ្សេងៗ ០,៩% និងក្រុមសុខាភិបាល ០,៦% ខណៈដែលក្រុមការសិក្សាមិនមានការប្រែប្រួល ។

ពិនិត្យលើបម្រែបម្រួលឆ្នាំលើឆ្នាំ ក្រាហ្វខាងក្រោម-ឆ្វេងបានបង្ហាញថា អត្រាអតិផរណាឆ្នាំលើឆ្នាំបានថយចុះបន្តិចមកវិញ បន្ទាប់ពីបានកើនឡើងគួរឲ្យកត់សម្គាល់កាលពីខែមុន ។ ជាក់ស្តែង អត្រាអតិផរណាបានកើនឡើងជាបន្តបន្ទាប់ពី ១,៨% ១,៩% និង ៣,៧% នាខែ សីហា កញ្ញា និងតុលា រៀងគ្នា ហើយបានប្រសើរបន្តិចត្រឹម ៣,២% នាខែ វិច្ឆិកា ។ ដោយឡែក បើពិនិត្យមើលអតិផរណាប្រចាំឆ្នាំ ក្នុងអំឡុងពេលដូចគ្នានារយៈកាល ៥ ឆ្នាំចុងក្រោយវិញ (ដូចបង្ហាញក្នុងក្រាហ្វខាងក្រោម-ស្តាំ) ស្ថានភាពអតិផរណានៅក្នុងឆ្នាំ ២០១០ នេះ មានសភាពនឹងនរល្អជាងគេ ដោយបានប្រែប្រួលក្នុងគម្លាតតូចពី ១,៦% ទៅ ៧,៣% ប៉ុណ្ណោះមកទល់នឹងខែវិច្ឆិកា ឆ្នាំ២០១០ នេះ ។ អតិផរណាប្រចាំឆ្នាំរំពឹងថានឹងស្ថិតក្នុងកម្រិតក្រោម ៥% នាដំណាច់ឆ្នាំ ២០១០ នេះ ។







កត្តាមួយចំនួនដែលបានរួមចំណែកក្នុងអតិផរណារួមប្រចាំឆ្នាំ នាខែវិច្ឆិកា ឆ្នាំ២០១០ ដែលស្មើនឹង ៣,២% គឺ ក្រុមម្ហូបអាហារ និងភេសជ្ជៈពុំមានជាតិស្រវឹង ១,៨% (ត្រូវនឹងសមាមាត្រ ៥៦,១% នៃអត្រាអតិផរណាប្រចាំឆ្នាំ) ក្រុមផ្ទះសម្បែង/ទឹក/អគ្គិសនី/ឧស្ម័ននិងឥន្ធនៈដទៃទៀត ០,៥% (ត្រូវនឹងសមាមាត្រ ១៤,៣%) ក្រុមដឹកជញ្ជូន ០,៣% (ត្រូវនឹងសមាមាត្រ ៨,៣%) ក្រុមភោជនីយដ្ឋាន ០,២% (ត្រូវនឹងសមាមាត្រ ៦,១%) និងក្រុមសម្លៀកបំពាក់ និង ស្បែកជើង ០,១% (ត្រូវនឹងសមាមាត្រ ២,២%) ។ ដោយឡែកមុខទំនិញ ៧ ក្រុមទៀត

| Contribution (YOY%) | Sep-10 | Oct-10 | Nov-10 |
|---|---|---|---|
| All Items | 1.9 | 3.7 | 3.2 |
| Food & N A B | 1.0 | 2.1 | 1.8 |
| Housing W E. | 0.4 | 0.6 | 0.5 |
| Transportation | 0.3 | 0.5 | 0.3 |
| Restaurants | 0.1 | 0.1 | 0.2 |
| Clothing & F. | -0.1 | 0.0 | 0.1 |
| Others | 0.2 | 0.3 | 0.3 |

ដែលនៅសល់បានចូលរួមចំណែក ០,៣% ប៉ុណ្ណោះ (ត្រូវនឹងសមាមាត្រ ៨,៤% នៃអត្រាអតិផរណាប្រចាំឆ្នាំ) ។




ទន្ទឹមនោះ ខណៈដែលអតិផរណារួមមានអត្រា ៣,២% ក្នុងខែវិច្ឆិកានេះ អតិផរណាឆ្នាំលើឆ្នាំមិនគិតថ្លៃទំនិញក្រុមម្ហូបអាហារមានអត្រា ២,៤% ។ រីឯអតិផរណាឆ្នាំលើឆ្នាំ មិនគិតថ្លៃទំនិញនិងសេវាពាក់ព័ន្ធនឹងថ្លៃប្រេងឥន្ធនៈ ដែលបញ្ចូលទាំងថ្លៃសេវាក្រុមដឹកជញ្ជូនផងនោះ មានអត្រា ២,៥% គឺទាបជាងអតិផរណារួមផងដែរ ។ ទិន្នន័យនេះបង្ហាញថាថ្លៃទំនិញក្រុមម្ហូបអាហារនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ ជាកត្តាចំបងជំរុញឲ្យអតិផរណារួមកាន់តែមានកម្រិតខ្ពស់ឡើង ក្នុងខែវិច្ឆិកានេះ ។ ម្យ៉ាងទៀតអត្រាអតិផរណាមិនរាប់បញ្ចូលថ្លៃម្ហូបអាហារ និងថ្លៃទំនិញនិងសេវាពាក់ព័ន្ធនឹងថ្លៃប្រេងឥន្ធនៈ មានកម្រិតត្រឹមតែ ០,៥% ពោលគឺ ទំនិញជាទូទៅផ្សេងៗទៀតមានការឡើងថ្លៃបន្តិចបន្តួចប៉ុណ្ណោះ ដែលអាចផ្តល់ការសន្និដ្ឋានថាតម្រូវការក្នុងស្រុករបស់អ្នកប្រើប្រាស់នៅមានកម្រិតទាប ។

## II. កត្តាសំខាន់ៗនៃអតិផរណា

### ១-កត្តាទំនិញ

*ទី១-កត្តាថ្លៃម្ហូបអាហារ និងប្រេងឥន្ធនៈ:*




ក្នុងការគណនាអតិផរណា ម្ហូបអាហារមានមេគុណខ្ពស់ជាងគេគឺ ៤៥% ខណៈប្រេងឥន្ធនៈមានមេគុណ ១៦% នៅក្នុងកន្ត្រក ទំនិញ-សេវា ។ ការប្រែប្រួលថ្លៃប្រេងឥន្ធនៈអាចមានឥទ្ធិពលយ៉ាងខ្លាំងទៅលើថ្លៃទំនិញផ្សេងៗទៀតដូចជា ថ្លៃភ្ជួររាស់ ដាំដុះ និងដឹកជញ្ជូន ដែលជាសមាសធាតុផ្សំក្នុងការធ្វើឲ្យថ្លៃម្ហូបអាហារប្រែប្រួល ផងដែរ ។

ក្នុងខណៈដែលសេដ្ឋកិច្ចពិភពលោកកំពុងងើបឡើងវិញ តម្រូវការប្រេងឥន្ធនៈរបស់សកលលោក ជាពិសេសសហរដ្ឋអាមេរិក និងចិនបានកើនឡើងយ៉ាងខ្លាំង ដែលជាហេតុធ្វើឲ្យថ្លៃប្រេងឥន្ធនៈនៅទីផ្សារអន្តរជាតិ និងក្នុងស្រុកបានកើនឡើងជាបន្តបន្ទាប់ពីកម្រិតទាបបំផុត ២៦ និង ៧៦ សេនដុល្លារក្នុងមួយលីត្រ នៅដំណាច់ឆ្នាំ ២០០៨ ទៅ ៥៦ និង ១០៨ សេនដុល្លារអាមេរិកក្នុងមួយលីត្រ នៅខែវិច្ឆិកា ឆ្នាំ២០១០ រៀងគ្នា ។ ម៉្យាងវិញទៀត នៅខែវិច្ឆិកា ឆ្នាំ២០១០ ថ្លៃប្រេងឥន្ធនៈនៅលើទីផ្សារពិភពលោក និងក្នុងស្រុកបានកើនឡើង ៨% និង ១២,៥% រៀងគ្នា បើធៀបនឹងខែដូចគ្នានាឆ្នាំមុន ។

*ទី២- កត្តាអតិផរណានៃប្រទេសជិតខាង និងនៃទំនិញនាំចូល*

សម្ពាធអតិផរណាប្រចាំឆ្នាំនៅប្រទេសថៃបានថមថយល្បឿនខ្លះក្នុងអំឡុងប៉ុន្មានខែចុងក្រោយ តែនៅមានកម្រិត ២,៨% នៅឡើយនាខែវិច្ឆិកានេះ ខណៈសម្ពាធអតិផរណានៅប្រទេសវៀតណាម និងចិនបានកើនឡើងយ៉ាងខ្លាំងរហូតដល់ ១១,១% និង ៥,១% រៀងគ្នា ។ ការកើនឡើងនៃអតិផរណារបស់ប្រទេសដែលជាដៃគូរពាណិជ្ជកម្មសំខាន់ជាមួយកម្ពុជានេះ បានជះឥទ្ធិពលលើទំនិញក្នុងស្រុករបស់កម្ពុជា ដែលជាកត្តាចូលរួមចំណែកក្នុងការធ្វើឲ្យអតិផរណារបស់កម្ពុជាក្នុងខែវិច្ឆិកានេះកើនឡើង ៣,២% ដែរ។




មួយវិញទៀត ដោយកម្ពុជាជាប្រទេសដុល្លារូបនីយកម្ម បម្រែបម្រួលនៃអត្រាប្តូរប្រាក់ដុល្លារអាមេរិកជាមួយ ប្រាក់យ៉ន់ចិន ប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម ក៏មានឥទ្ធិពលផងដែរមកលើកម្រិតអតិផរណារបស់ប្រទេសកម្ពុជា ។ ការឡើងថ្លៃជាលំដាប់នៃប្រាក់យ៉ន់ចិន និងប្រាក់បាតថៃធៀបនឹងប្រាក់ដុល្លាអាមេរិកក៏បានធ្វើឲ្យអតិផរណាក្នុងស្រុករបស់កម្ពុជាកើនឡើងដែរ ។

**២- ភត្ថាតម្រូវភារ និ១រូបិយទត្ថុ** : សភាពប្រសើរឡើងនៃទិដ្ឋភាពសេដ្ឋកិច្ចសកលលោក រួមទាំងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា បានចូលរួមបង្កើនទំនុកចិត្តវិស័យឯកជនមកលើប្រព័ន្ធធនាគារ ហើយបានរួមចំណែកធ្វើឲ្យការអភិវឌ្ឍរូបិយវត្ថុក្នុងប្រទេសមានសន្ទុះជាធម្មតាឡើងវិញ ។ ការវិវឌ្ឍប្រសើរឡើងនៃសូចនាកររូបិយវត្ថុសំខាន់ៗត្រូវបានឆ្លុះបញ្ចាំងដូចខាងក្រោម ៖

- អត្រាកំណើនរូបិយវត្ថុទូទៅ (M2) ឆ្នាំលើឆ្នាំនាខែវិច្ឆិកា ឆ្នាំ២០១០ នេះ ស្មើ ២៣% ធៀបនឹង ២៦% នាខែតុលា កន្លងទៅ ។ រូបិយវត្ថុទូទៅនេះធ្លាប់មានកំណើនដល់ទៅ ៣៤% នាខែវិច្ឆិកា ឆ្នាំ២០០៩ និងមានកំណើនត្រឹមតែ ៨% ប៉ុណ្ណោះនារយៈពេលដូចគ្នា ឆ្នាំ២០០៨ ។ ប្រភពចម្បងនៃកំណើនក្នុងខែវិច្ឆិកា ឆ្នាំ២០១០ នេះ គឺប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស ដែលមានកំណើន ២៧% ហើយបានរួមចំណែក ២២% ទៅក្នុងកំណើនរូបិយវត្ថុទូទៅ ២៣% នោះ ។

- អត្រាកំណើនប្រចាំឆ្នាំនៃទ្រព្យសកម្មបរទេសសុទ្ធស្មើ ១៤% នាខែវិច្ឆិកា ឆ្នាំ២០១០ ដែលជាកំណើនមួយទាបជាងកំណើន ២២% នៃខែតុលាកន្លងទៅ ។ ទ្រព្យសកម្មបរទេសសុទ្ធធ្លាប់មានកំណើនដល់ទៅ ៥១% នាគ្រាដូចគ្នា ឆ្នាំ២០០៩ និងបានថយចុះដល់ទៅ ៧% នាគ្រាដូចគ្នា ឆ្នាំ២០០៨ ។ ប្រភពចម្បងនៃកំណើនក្នុងឆ្នាំនេះគឺកំណើនទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា ដែលរួមចំណែក ១០% នៃកំណើនរូបិយវត្ថុទូទៅ (M2) និងទ្រព្យសកម្មបរទេសសុទ្ធរបស់គ្រឹះស្ថានធនាគារ ដែលរួមចំណែក ៥% នៃកំណើនរូបិយវត្ថុទូទៅ (M2) ។ ក្នុងរយៈពេល១១ខែ ដើមឆ្នាំ២០១០ នេះ ទ្រព្យសកម្មបរទេសសុទ្ធមានអត្រាកំណើនមធ្យមប្រចាំឆ្នាំ

ស្មើនឹង ៣០% ធៀបនឹងអត្រាកំណើនមធ្យមប្រចាំឆ្នាំ ១៧% នារយៈពេលដូចគ្នា ឆ្នាំ២០០៩ និង ២៤% នារយៈពេលដូចគ្នា ឆ្នាំ២០០៨ ។







- ប្រាក់បញ្ញើអតិថិជនក្នុងប្រព័ន្ធធនាគារនៅខែកញ្ញានេះ មានអត្រាកំណើនឆ្នាំលើឆ្នាំស្មើនឹង ២៧% ទាបជាងអត្រាកំណើននាខែតុលា ឆ្នាំ ២០១០ ។ អត្រាកំណើននេះធ្លាប់មានដល់ទៅ ៣៥% នាគ្រាដូចគ្នា ឆ្នាំ២០០៩ និងមានត្រឹមតែ ៦% ប៉ុណ្ណោះនាគ្រាដូចគ្នាឆ្នាំ ២០០៨ ។ បើគិតតាមអត្រាកំណើនមធ្យមប្រចាំឆ្នាំវិញ ប្រាក់បញ្ញើសរុបរយៈពេល ១១ ខែ ដើមឆ្នាំ ២០១០ នេះ ស្មើនឹង ៣៦% ធៀបនឹងកំណើន ១១% នារយៈពេលដូចគ្នាឆ្នាំ ២០០៩ ។

- អត្រាកំណើនឆ្នាំលើឆ្នាំនៃឥណទានចំពោះវិស័យឯកជនមានល្បឿនកើនឡើងជាបន្តបន្ទាប់ក្នុងរយៈពេល ១១ ខែចុងក្រោយនេះ ដែលក្នុងអំឡុងពេលពីរខែនេះ គឺខែតុលា និងខែវិច្ឆិកា ឆ្នាំ២០១០ មានកំណើនប្រហាក់ប្រហែលគ្នាគឺ ២៤,៨% និង ២៤,៣% រៀងគ្នា ។ កំណើននេះធ្លាប់មានដល់ ៣៤% នាគ្រាដូចគ្នាឆ្នាំ ២០០៩ ។ បើគិតតាមអត្រាកំណើនមធ្យមប្រចាំឆ្នាំវិញ ក្នុងរយៈពេល១១ខែ ឆ្នាំ២០១០នេះ ឥណទានចំពោះវិស័យឯកជនមានកំណើនស្មើនឹង ១៨% ដែលកំណើននេះធ្លាប់មានត្រឹមតែ ១៤% នាគ្រាដូចគ្នាឆ្នាំ២០០៩ ។

- ទុនបម្រុងផ្លូវការសុទ្ធ គិតត្រឹមថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១០ នេះ មានទំហំ ២.៥០២ លានដុល្លារ ពោលគឺបានកើនឡើងចំនួន ២៤៣ លានដុល្លារ ធៀបនឹងដំណាច់ឆ្នាំ ២០០៩ ។ ទន្ទឹមនោះដែរ ទុនបម្រុងអន្តរជាតិដុលមានទំហំ ២.៦០៨ លានដុល្លារ ពោលគឺបានកើនឡើងចំនួន ២៤០ លានដុល្លារ ធៀបនឹងដំណាច់ឆ្នាំ ២០០៩ ។



## III. ជំហរគោលនយោបាយរូបិយវត្ថុ និងសកម្មភាពចំពោះមុខ

### ១.បរិបទនៃប្រទេសជិតខាងនិងសកលលោក

ថ្មីៗនេះ មូលនិធិរូបិយវត្ថុអន្តរជាតិបានកែតម្រូវការព្យាករណ៍របស់ខ្លួនថា កំណើនសេដ្ឋកិច្ចសកលលោក សេដ្ឋកិច្ចប្រទេសជឿនលឿន និងសេដ្ឋកិច្ចប្រទេសកំពុងងើបឡើងនិងកំពុងអភិវឌ្ឍន៍ អាចនឹងកើនរហូតដល់ ៤,៨% ២,៧% និង ៧,១% នៅឆ្នាំ២០១០ រៀងគ្នា។ ចំណែកសហរដ្ឋអាមេរិកដែលជាក្បាលម៉ាស៊ីនសេដ្ឋកិច្ចសកលលោករំពឹងថានឹងមានកំណើនរហូតដល់ ២,៧% នៅឆ្នាំ ២០១០ នេះ ខណៈដែលកំណើនសេដ្ឋកិច្ចប្រទេសចិន ឥណ្ឌា និងសេដ្ឋកិច្ចឧស្សាហកម្មថ្មីៗនៅអាស៊ី និងអាស៊ាន-៥ នឹងឈានដល់ ១០,៥% ៩,៧% ៧,៨% និង ៦,៧% រៀងគ្នា នៅឆ្នាំ២០១០ ។




ជាក់ស្តែង កំណើនប្រចាំឆ្នាំនៃសេដ្ឋកិច្ចរបស់ប្រទេសជឿនលឿនដូចជា សហរដ្ឋអាមេរិក និងជប៉ុន បានកើនឡើងពី ១,៧% និង ០,៣៧% ក្នុងត្រីមាសទី២ ទៅ ២,៦% និង ១,១% ក្នុងត្រីមាសទី៣ ឆ្នាំ ២០១០ រៀងគ្នា ក្នុងខណៈដែលកំណើនប្រចាំឆ្នាំ នៃសេដ្ឋកិច្ចរបស់ប្រទេសជឿនលឿនមួយចំនួនទៀត ដូចជា ប្រទេសអូស្ត្រាលី និងសហភាពអឺរ៉ុបបានថយចុះពី ១,២% និង ១% ក្នុងត្រីមាសទី ២ មក ០,២% និង ០,៤% ក្នុងត្រីមាសទី ៣ ឆ្នាំ២០១០ រៀងគ្នា ។ លើសពីនេះទៀត សេដ្ឋកិច្ចប្រទេសអាឡឺម៉ង់ដែលជាក្បាលម៉ាស៊ីននៃ កំណើនសេដ្ឋកិច្ចអឺរ៉ុបបានថយចុះគួរឲ្យកត់សំគាល់ ពោលគឺពី ២,៣% នៅត្រីមាសទី ២ មក ០,៧% នៅត្រីមាស ទី៣ ឆ្នាំ ២០១០ នេះ ។

រីឯសេដ្ឋកិច្ចក្នុងតំបន់វិញ កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំនៃប្រទេសឥណ្ឌា និងឥណ្ឌូណេស៊ីបានកើនឡើងជាលំដាប់ពី ៦,៥% និង -២,៤% នៅត្រីមាសទី៤ ឆ្នាំ ២០០៩ ទៅ ៨,៩% និង ៣,៤៥% នៅត្រីមាសទី៣ ឆ្នាំ២០១០ រៀងគ្នា ខណៈដែលកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំនៃប្រទេសចិនបានបន្តធ្លាក់ចុះពី ១១,៩% នៅត្រីមាសទី១ មក ១០,៣% នៅត្រីមាសទី២ និងមក ៩,៦% នៅត្រីមាសទី៣ ឆ្នាំ២០១០ ។ ជាងនេះទៀត កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំនៃប្រទេសជិតខាងកម្ពុជាដូចជាថៃបានកើនឡើងពី -០,៦% ត្រីមាសទី២ ទៅ -០,២% នៅត្រីមាសទី៣ ឆ្នាំ២០១០ បន្ទាប់ពីធ្លាក់ចុះពី ៣,៨% នៅត្រីមាសទី១ ឆ្នាំ២០១០ ។




ក្នុងខណៈពេលសេដ្ឋកិច្ចនៃប្រទេសជឿនលឿននិងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនមានកំណើនកើនឡើង និងខ្លះទៀតមានកំណើនធ្លាក់ចុះនៅក្នុងត្រីមាសទី ៣ នេះ ប្រទេសមួយចំនួនអាចគ្រប់គ្រងអតិផរណារបស់គេបានយ៉ាងល្អ ពោលគឺអតិផរណារបស់ប្រទេសថៃ ហ្វីលីពីន និងឥណ្ឌាបានធ្លាក់ចុះពី ៣,៤៦% នៅកក្កដា ៤%

នៅខែសីហា ១៦,២% នៅខែមករា មក ២,៨៦% ២,៨% និង៩,៧% នៅខែវិច្ឆិកា ឆ្នាំ ២០១០ រៀងគ្នា ។ ចំណែកអតិផរណារបស់សហរដ្ឋអាមេរិកស្ថិតក្នុងរង្វង់ទាបប្រមាណ ១,១% ក្នុងអំឡុងខែមិថុនា-ធ្នូ ឆ្នាំ២០១០ នេះ ដូច្នេះប្រទេសទាំងនេះនៅរក្សាគោលនយោបាយរូបិយវត្ថុពង្រីករបស់គេជាបន្តទៀត ពោលគឺសហរដ្ឋអាមេរិក និងឥណ្ឌូណេស៊ី នៅរក្សាអត្រាគោលនយោបាយក្នុងរង្វង់ ០,២៥% និង ៦,៥% ក្នុងអំឡុងខែមករា ឆ្នាំ ២០០៩-ខែធ្នូ ឆ្នាំ២០១០ និងខែសីហា ឆ្នាំ២០០៩-ខែធ្នូ ឆ្នាំ២០១០ រៀងគ្នា ។ ម្យ៉ាងវិញទៀតការធ្លាក់ចុះនៃអត្រាអតិផរណានាពេលថ្មីនេះរបស់ប្រទេសថៃនិងឥណ្ឌាក៏ជាលទ្ធផលនៃការអនុវត្តន៍គោលនយោបាយរូបិយវត្ថុរឹតត្បិតដោយតម្លើងអត្រាការប្រាក់គោលនយោបាយរបស់គេ ពោលគឺប្រទេសថៃបានតម្លើងអត្រាគោលពី ១,២៥% នៅខែមិថុនា ទៅ ១,៥% នៅខែកក្កដា ទៅ ១,៧៥% នៅខែសីហា និងទៅ ២% នៅខែ ធ្នូ ឆ្នាំ២០១០ ។ ដូចគ្នានោះដែរ ក្រុមប្រឹក្សាភិបាលរបស់ធនាគារកណ្តាលឥណ្ឌាក៏បានអនុវត្តគោលនយោបាយរឹតត្បិតជាបន្តបន្ទាប់ ដោយតម្លើងអត្រាការប្រាក់គោលពី ៣,២៥% ក្នុងអំឡុងខែឧសភា ឆ្នាំ ២០០៩ - កុម្ភៈ ឆ្នាំ ២០១០ ទៅ ៥,២៥% ក្នុងអំឡុងពេលពីរខែចុងក្រោយនៃឆ្នាំ ២០១០ នេះ ។

ម្យ៉ាងវិញទៀតអតិផរណារបស់ប្រទេសមួយចំនួនដូចជាឥណ្ឌូណេស៊ី វៀតណាម ចិន ជប៉ុន និងសហ-គមន៍អឺរ៉ុប ក៏ចាប់ផ្តើមមាននិន្នាការកើនឡើងដែរ ជាអាទិ៍អតិផរណារបស់ប្រទេសឥណ្ឌូណេស៊ីស្ថិតក្នុងកម្រិតខ្ពស់ស្មើនឹង ៥,៨% ក្នុងអំឡុងពេលខែមិថុនា-វិច្ឆិកា ឆ្នាំ២០១០ ហើយអតិផរណាប្រចាំឆ្នាំនៃប្រទេសមហាអំណាចអាស៊ីទី ១ ចិនបានកើនឡើងពី ១,៥% នៅខែមករា ឆ្នាំ២០១០ មក ៥,១% នៅខែវិច្ឆិកា ឆ្នាំ២០១០ និងអតិផរ-ណារបស់វៀតណាមបានកើនឡើងជាបន្តបន្ទាប់ពី ១,៩៧% នៅខែសីហា ឆ្នាំ២០០៩ រហូតទៅដល់ ១១,០៩% នៅខែវិច្ឆិកា ឆ្នាំ២០១០ ។ ដើម្បីទប់ការកើនឡើងអតិផរណានេះ គណៈកម្មការគោលនយោបាយរូបិយវត្ថុរបស់ប្រទេសនេះក៏បានសម្រេចចិត្តចាប់ផ្តើមអនុវត្តគោលនយោបាយរូបិយវត្ថុរឹតត្បិតតាមរយៈការបង្កើនអត្រាការប្រាក់គោលរបស់គេ ពោលគឺប្រទេសចិន បានបង្កើនអត្រាការប្រាក់គោលនយោបាយពី ៥,៣១% នៅអំឡុងខែមករា ឆ្នាំ ២០០៨ - ខែកញ្ញា ឆ្នាំ ២០១០ និងទៅ ៥,៥៦% នៅក្នុងអំឡុងខែតុលា-ធ្នូ ឆ្នាំ ២០១០ រីឯប្រទេសវៀតណាមបានបង្កើនអត្រាការប្រាក់គោលនយោបាយពី ៦% ក្នុងអំឡុងពេលខែធ្នូឆ្នាំ២០០៩-ខែកញ្ញា ឆ្នាំ២០១០ ទៅ ៧% ក្នុងអំឡុង ខែតុលា-ធ្នូ ឆ្នាំ ២០១០ ។






២- បរិបទនៃប្រទេសកម្ពុជា

ក-ស្ថានភាពសេដ្ឋកិច្ច

- កំណើនសេដ្ឋកិច្ច

កំណើនសេដ្ឋកិច្ចសកលោកបានជួយធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាមានសន្ទុះកើនឡើងគួរឲ្យកត់សំគាល់ ពោលគឺសេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករណ៍នារយៈពេលថ្មីៗនេះថានឹងមានកំណើនប្រចាំឆ្នាំ ៥% នៅឆ្នាំ២០១០ ។ ជាក់ស្តែង ទិន្នន័យថ្មីៗបានបង្ហាញថាកំណើននៃការនាំចេញ ការនាំចូល ការវិនិយោគផ្ទាល់បរទេសសុទ្ធ និងភ្ញៀវទេសចរនៅក្នុង ៩ ខែ ឆ្នាំ២០១០ មានកម្រិតលើសពី ១៨%, ១៤%, ៤១%, និង១៥% រៀងគ្នាធៀបនឹងរយៈពេលដូចគ្នានាឆ្នាំ២០០៩ ។

- ស្ថានភាពអត្រាប្តូរប្រាក់




រយៈពេលប៉ុន្មានខែចុងក្រោយប្រាក់រៀលបានឡើងថ្លៃធៀបជាមួយប្រាក់ដុល្លារអាមេរិក ជាពិសេសនាពេលពីរខែចុងក្រោយ ។ ផ្អែកលើអត្រាចុងគ្រា ៤.០៥០ រៀលក្នុងមួយដុល្លារ ប្រាក់រៀលបានឡើងថ្លៃប្រមាណ ៣% នាឆ្នាំនេះ ។ តែគិតតាមអត្រាមធ្យមប្រចាំខែ ប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបានចុះថ្លៃប្រមាណ ១,៣ % គឺប្រហាក់ប្រហែលនឹងបម្រែបម្រួលនាឆ្នាំមុនៗ ។ ការធ្វើអន្តរាគមន៍ដ៏សកម្មរបស់ធនាគារជាតិនៃកម្ពុជានាអំឡុងខែ ឧសភា-កញ្ញា ឆ្នាំ ២០១០ ដោយលក់ប្រាក់ដុល្លារចំនួន ៤៨ ដង មានទឹកប្រាក់ ៤៨ លានដុល្លារ បានជួយទ្រទ្រង់ដល់ស្ថិរភាពអត្រាប្តូរប្រាក់នាអំឡុងពេលនោះមួយកម្រិត ខណៈកត្តារដូវកាលអាចជាមូលហេតុសំខាន់នៃការឡើងថ្លៃប្រាក់រៀលនាពេលចុងឆ្នាំ ។

នៅក្នុងអំឡុងពេលដូចគ្នានេះដែរ បើធៀបនឹងរូបិយប័ណ្ណនៃបណ្តាប្រទេសជាដៃគូពាណិជ្ជកម្មមួយចំនួន ប្រាក់រៀលបានចុះថ្លៃ ៩,៦% ៧,៩% ២,១% និង ១% ធៀបនឹងប្រាក់បាតថៃ ប្រាក់ដុល្លារសឹង្ហបុរី ប្រាក់យ៉ន់ចិន និងប្រាក់ដុល្លារហុងកុង រៀងគ្នា ធៀបនឹងរយៈពេលដូចគ្នានាឆ្នាំ ២០០៩ ។ ផ្ទុយទៅវិញ ប្រាក់រៀលបានឡើងថ្លៃជាមធ្យម ៥,៨% ធៀបនឹងប្រាក់ដុងវៀតណាមនារយៈពេលដូចគ្នានេះ ។

- ចលនាអត្រាការប្រាក់




ទន្ទឹមនឹងសេដ្ឋកិច្ចពិភពលោកកំពុងងើបឡើង សេដ្ឋកិច្ចក្នុងស្រុកក៏មានសភាពល្អប្រសើរឡើងដែរ ហើយ តម្រូវការសាច់ប្រាក់ក្នុងវិស័យឯកជនចាប់ផ្តើមមានជាបន្តបន្ទាប់ក្នុងពេលបច្ចុប្បន្ននេះ ។ ស្របគ្នានោះដែរកំណើនប្រាក់បញ្ញើអតិថិជន និងការតំឡើងដើមទុនរបស់ធនាគារពាណិជ្ជបានធ្វើឲ្យសាច់ប្រាក់ងាយស្រួលរបស់ប្រព័ន្ធធនាគារកាន់តែល្អថែមទៀត ដែលនាំឲ្យគ្រឹះស្ថានធនាគារកាត់បន្ថយអត្រាការប្រាក់បញ្ញើរបស់ខ្លួនជាបន្តទៀត ។ ពិនិត្យបម្រែបម្រួលពីដំណាច់ឆ្នាំកន្លងទៅមកទល់ខែវិច្ឆិកា អត្រាការប្រាក់រយៈពេល ៦ ខែ មានការវិវត្តដូចតទៅ:

- អត្រាថ្លឹងចំពោះប្រាក់បញ្ញើជារៀល បានកើនពី ៥,៣% ដល់ ៥,៥%
- អត្រាថ្លឹងចំពោះប្រាក់កម្ចីជារៀល បានថយចុះពី ២២,៦% ដល់ ២២,១%
- អត្រាថ្លឹងចំពោះប្រាក់កម្ចីជាប្រាក់ដុល្លារ បានកើនពី ១៧,២% ដល់ ១៨,៩% និង
- អត្រាថ្លឹងចំពោះប្រាក់បញ្ញើជាដុល្លារ បានថយចុះពី ៤,៣% ដល់ ៣,៥% ។

- ស្ថានភាពឥណទានមិនដំណើរការ




ក្នុងខែតុលា ឆ្នាំ ២០១០ នេះ ស្ថានភាពឥណទានមិនដំណើរការបានធ្លាក់ចុះទៀតរហូតដល់ ៣,៦% ធៀបនឹង ៦% កាលពីខែដូចគ្នានាឆ្នាំមុន ខណៈឥណទានចំពោះវិស័យឯកជនបានកើនឡើងដល់ ២៤,៨% ឆ្នាំលើឆ្នាំនៅខែតុលា ធៀបនឹងកំណើនត្រឹមតែ ២,៧% ប៉ុណ្ណោះ កាលពីខែដូចគ្នា ឆ្នាំ ២០០៩ ។ ការកើនឡើងនៃឥណទានចំពោះវិស័យឯកជន និងការធ្លាក់ចុះនៃឥណទានមិនដំណើរការឆ្លុះបញ្ចាំងនូវការខិតខំរបស់គ្រឹះ-ស្ថានធនាគារក្នុងការគ្រប់គ្រងបំណុល ដែលអំណោយផលផងដែរ ដោយការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជា ។